00750728

E131/2/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 11 / 2011
ម៉ោង (Time/Heure): 9:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

## អង្គជំនុំជម្រះសាលាដំបូង-អនុស្សរណៈ

សាធារណៈ / Public

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់ជនជាប់ចោទ នួន ជា ដែលស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ជាបណ្តោះអាសន្ន**

យោងសំណើរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ដែលស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ជាបណ្តោះអាសន្ន ដោយហេតុថាកិច្ចស៊ើបសួរដែលសហចៅក្រមស៊ើបអង្កេតបានបំពេញនៅក្នុងសំណុំរឿងនេះពុំមានភាពយុត្តិធម៌ (ឯកសារ E131/2)។ នាពេលថ្មីៗកន្លងទៅអង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើបញ្ហានេះរួចហើយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E116)។ នាពេលបច្ចុប្បន្នសេចក្តីសម្រេចនេះជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ នៅក្នុងសំណើសុំមុនរបស់ខ្លួន (ឯកសារ E51/3) មេធាវីការពារក្តី នួន ជា បានលើកបញ្ហាអង្គហេតុស្រដៀងគ្នានេះ និងបានស្នើសុំដំណោះស្រាយតែមួយដូចគ្នានឹងអ្វីដែលខ្លួនកំពុងស្នើនេះ។ បញ្ហាស្រដៀងគ្នាទាំងអស់នេះក៏ធ្លាប់ត្រូវបានអង្គជំនុំជម្រះផ្សេងៗនៅ អ.វ.ត.ក លើកយកមកពិនិត្យពិចារណារួចហើយ (*សូមមើល ឧទាហរណ៍* ឯកសារ D171/5, D171/4/5/, E93/4, E93/9, E116/1/1)។

នៅពេលនេះ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីជាបណ្តោះអាសន្នរហូតដល់ពេល (១) មានសាលដីការបស់អង្គជំនុំតុលាការកំពូលលើបណ្តឹងសាទុក្ខរបស់ខ្លួនជំទាស់នឹងសេចក្តីសម្រេច E116 និងមានការសម្រេចលើបណ្តឹងព្រហ្មទណ្ឌដោយសាលាដំបូងរាជធានីភ្នំពេញ (២) "មានការវាយតម្លៃដោយឯករាជ្យ និងគ្រប់ជ្រុងជ្រោយទៅលើលទ្ធភាពរបស់ អ.វ.ត.ក ក្នុងការផ្តល់យុត្តិធម៌"។ វិធាន ១០៤ នៃវិធានផ្ទៃក្នុងចែងច្បាស់ថាបណ្តឹងសាទុក្ខភ្លាមៗមិនមានអានុភាពបង្អង់នីតិវិធីមុខអង្គជំនុំជម្រះសាលា

ដំបូងទេ។ ក្រុមខណ្ឌគតិយុត្ត អ.វ.ត.ក ក៏ពុំបានថ្លែងអំពីការបង្អង់នីតិវិធី ដើម្បីរង់ចាំសេចក្តីសម្រេចរបស់តុលាការជាតិដែរ។ មេធាវីការពារក្តីជនជាប់ចោទ នួន ជា ពុំបានបញ្ជាក់ច្បាស់លាស់ឡើយថាអ្វីទៅជា "ការវាយតម្លៃដោយឯករាជ្យ" ទៅលើអង្គជំនុំជម្រះសាលាដំបូងដែលខ្លួនចង់បាន ហើយអ្នកណាជាអ្នកវាយតម្លៃ។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាពុំមានមូលដ្ឋានណាមួយដែលត្រូវបង្អង់កិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ជាបណ្តោះអាសន្នឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំ E131/2។

នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើសុំ E131/2។